ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 09 / 2012
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ៍ ទី ២១ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៩៩

រៀបចំដោយ: សែ គុលវុឌ្ឍី និង Roger PHILLIPS

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោកស្រី សែ គុលវុឌ្ឍី, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ាត់, លោក Tarik ABDULHAK, លោក RAYNOR Keith, |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Jasper PAUW, លោក សុន អារុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |

00844095



| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី ស៊ិន សុវន, លោក វ៉េន ពៅ, លោកស្រី Beini YE, លោក ហុង គីមសួន |
| សាក្សី៖ ស សៀក ហៅស៊ីម (TCW-609) និង គីម វុន (TCW-338) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា លី និមល (ជំនួយការរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ), កញ្ញា Anne-Elise JOLICARD, កញ្ញា ហ៊ីង វ៉ាន់ដាណែត |

**<u>ពេលវេលាទូទៅរបស់តុលាការ៖</u>**

| | | |
|---|---|---|
| ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង និង ០៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០១<br>១២.០២ | ០៩.០៤<br>១២.០៤ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី ស សៀក ហៅស៊ីម (TCW-609) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៤<br>០៩.៣៣<br>០៩.៤៩ | ០៩.៣៣<br>០៩.៤៨<br>១០.៣៥ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី គីម វុន (TCW-338) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១០.៥៩<br>១១.១៣ | ១១.១៣<br>១៦.១០ |
| សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងពេលវេលាបន្ថែម | អង្គជំនុំជម្រះ | ១៥.០៣ | ១៥.១១ |
| សេចក្តីសម្រេចលើការជំទាស់របស់មេធាវី | អង្គជំនុំជម្រះ | ១៥.៤០ | ១៥.៤៩ |

| ការពារក្តី នួន ជា | | | |
|---|---|---|---|

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី និង នួនជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ (ជនជាប់ចោទ អៀង សារី សម្រាប់រយៈពេលពេញមួយថ្ងៃ ហើយ ជនជាប់ចោទ នួន ជា សម្រាប់រយៈពេលមួយរសៀល) ។

**<u>ការតាំងសំណួរទៅកាន់សាក្សី ស សៀក ហៅស៊ុម (TCW-609)</u>**

មេធាវីការពារក្តី នួន ជា បានចាប់ផ្តើមតាំងសំណួរទៅសាក្សី បន្ទាប់មកមេធាវីការពារក្តី អៀង សារី និង បន្ទាប់មកមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅសាក្សី។

**<u>ការតាំងសំណួរទៅកាន់សាក្សី គីម វុន (TCW-338)</u>**

ប្រធានអង្គជំនុំជម្រះ បានតាំងសំណួរបឋមទៅកាន់សាក្សីទាក់ទងនឹងប្រវត្តិសាវតារបស់សាក្សី ហើយបាន ប្រាប់អំពីសិទ្ធិនិងករណីកិច្ចរបស់សាក្សី បន្ទាប់មកសហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី។

**<u>សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងពេលវេលាបន្ថែម</u>**

សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាបន្ថែមមួយថ្ងៃកន្លះសម្រាប់ចែករំលែកជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរទៅសាក្សី គីម វុន។ អង្គជំនុំជម្រះបានសម្រេចថាពេលវេលាដែលបានបែងចែកឱ្យទៅភាគីក្នុងការតាំងសំណួរទៅកាន់សាក្សីណាម្នាក់គឺអាចប្រើប្រាស់សម្រាប់តែសាក្សីនោះប៉ុណ្ណោះ ភាគីមិនអាចយកទៅប្រើប្រាស់សម្រាប់ការតាំងសំណួរទៅសាក្សីផ្សេងនោះទេ។

**<u>សេចក្តីសម្រេចលើការជំទាស់របស់មេធាវី ការពារក្តី នួន ជា</u>**

មេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានសម្រេចថាភាគីដែលស្នើសុំដាក់ឯកសារ ដំបូងត្រូវតែសួរទៅកាន់សាក្សីជាមុនសិនថា តើសាក្សីធ្លាប់បានឃើញឯកសារនោះពីមុនមកដែរឬទេ ហើយប្រសិនបើសាក្សីបញ្ជាក់ថាមិនដែលបានឃើញទេ ឯកសារនោះត្រូវតែដកចេញពីសាក្សីភ្លាម ពីព្រោះដើម្បីកុំឱ្យសាក្សីមានការភាន់ច្រឡំ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/379 | D200/6 | 00294797-00294815 00323321-00323339 00385192-00385212 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SÂ Siek ស សៀក [Surrogate Sheet] Written Record of interview of SÂ Siek ស សៀក [Feuille remplacée] Procès verbal d'audition de témoin SÂ Siek ស សៀក | P | 00294803, 00294798, 00294797, 00294814 | 00323327, 00323322-00323323 | 00385199, 00385193, 00385192, 00385211 |
| E3/1725 | D200/6.8 | 00833490-00833497 00834863-00834870 00835914-00835921 | [កែតម្រូវ ១] ប្រតិចារឹកបទសម្ភាសន៍ជាមួយអ្នកស្រី ស សៀក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ Transcript of recorded interview with SÂ Siek dated 24 March 2009 Transcription d'audition de SÂ Siek en date du 24 mars 2009 | P | 00833497, 00833490 | 00834870, 00834863 | 00835921, 00835914 |
| E3/380 | D201/10 | 00357195-00357202 00365640-00365647 00485428-00485434 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី KIM Vun គឹម វុន ចុះថ្ងៃទី 25-07-2009 [Surrogate Sheet] Written Record of Interview of KIM Vun គឹម វុន dated 25 July 2009 [Feuille remplacée] Procès verbal d'audition de témoin KIM Vun គឹម វុន en date du 25 Juillet 2009 | P | 00357197, 00357200, 00357202 | 00365642, 00365645 | 00485429, 00485429-00485430, 00485433 |
| E3/637 | D366/7.1.560 | 00442326-00442358 00740931-00740970 00752169-00752204 | [លិខិតបញ្ជាក់ការជំនួសឯកសារ] សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន, ហ៊ូ នឹម, និង ហ៊ូ យន់ [Surrogate Sheet] Statement of Khieu Samphan, Hou Yun, Hu Nim [Feuille remplacée] Déclaration de KHIEU Samphan, Hou Yun, Hu Nim | P | 00442332, 00442328 | 00740938, 00740933 | 00752174, 00752170 |
| E3/381 | D201/11 | 00357203-00357207 00365526-00365530 00402996-00403000 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី KIM Vun គឹម វុន ចុះថ្ងៃទី 28-07-2009 [Surrogate Sheet] Written Record of Interview of KIM Vun គឹម វុន dated 28 July 2009 [Feuille remplacée] Procès verbal d'audition de témoin KIM Vun គឹម វុន en date du 28 Juillet 2009 | P | 00357205 | 00365528 | 00402997-00402998 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/5 | D243/ 2.1.1 | 00063311-00063353 00401476-00401511 00538951-00538985 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ទង់បដិវត្ត លេខ 8 សីហា 1975<br>[Surrogate Sheet] CPK Magazine entitled: " The Revolutionary Flag", Issue 8, August 1975 (FULL)<br>[Feuille remplacée] CPK Magazine entitled: " The Revolutionary Flag", Issue 8, August 1975 (FULL) | P | 00063311, 00063324, 00063341 | 00401476, 00401488, 00401501 | 00538951, 00538963, 00538976 |
| E3/262 | 12.16 | 00622985-00622992 00528388-00528393 S 00004705-00004709 | ការប្រជុំពេញអង្គលើកទី១ នីតិកាលទី១ នៃសភាតំណាងប្រជាជននៃកម្ពុជា សេចក្តីប្រកាសព័ត៌មានថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦<br>First plenary session of the first legislature of the people representative assembly of Kampuchea, Press Release 14 April 1976<br>First plenary session of the first legislature of the people representative assembly of Kampuchea, Press Release 14 April 1976 | P | 00622986, 00622989, 00622990 | 00528389, 00528391, 00528392 | 00004706, 00004708, 00004709 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (០៩.០៤) និង នួន ជា (១២.០៥) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- អង្គជំនុំជម្រះបានសម្រេចថាចំពោះការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ សម្រាប់ជាភស្តុតាង ហើយដែលបានបង្ហាញទៅភាគីនោះ ភាគីអាចយកខ្លឹមសារនៃឯកសារនោះជាមូលដ្ឋានសម្រាប់ចោទសួរ។ ឯកសារនោះអាចដាក់ជូនទៅសាក្សីបានប្រសិនបើគាត់មានភាពពាក់ព័ន្ធផ្ទាល់ទៅលើបញ្ហានោះ
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្របសម្រួលជូនសាក្សី ស សៀក ហៅស៊ឹម ត្រឡប់ទៅកាន់គេហដ្ឋានរបស់គាត់វិញ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញសម្របសម្រួលជូនសាក្សី គីម វុន ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២។

| |
|---|
| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
| សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ២២ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលវុឌ្ឍី Roger PHILLIPS